អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# តើអ្នកពូកែអី?

# What are you good at?

Written by TukTuk

Illustrated by Choven Hen







នារសៀលថ្ងៃមួយ យ៉េកកំពុងដឹកខេទីនិងលោកគ្រូសុខនៅលើរ៉ឺម៉កកង់បីរបស់គាត់ ដើម្បីដិះដើរលេង។
ស្រាប់តែពួកគាត់បានប្រទះឃើញរតនានិងមករាកំពុងលេងនៅតាមផ្លូវ។



ខេទីក៏ស្រែកសួរ « តើអ្នកទាំងពីរចង់ឡើងមកជិះរ៉ឺម៉កកង់បី ដើរលេងជាមួយពួកយើងដែរឬទេ? »
ឮដូចនេះ កុមារទាំងពីរនាក់សប្បាយត្រេកអរយ៉ាងខ្លាំង ហើយក៏ហក់ឡើងរ៉ឺម៉កកង់បី ជាមួយពួកគេតែម្តង។




ខណៈពេលដែលពួកគាត់ទាំងអស់គ្នា កំពុងជិះរ៉ឺម៉កកង់បីដើរលេង ស្រាប់តែតនាប្រាប់យ៉េកនិងខេទី
« ខ្ញុំពូកែគណិតណាស់។ ថ្ងៃនេះ ថ្នាក់របស់ខ្ញុំប្រឡង ហើយខ្ញុំបានលេខមួយទៀតហ៎! »




មករាក៏និយាយ « ឯខ្ញុំវិញពូកែភាសាខ្មែរ ខាងប្រកបពាក្យខ្លាំងណាស់។
ថ្ងៃនេះ ថ្នាក់របស់ខ្ញុំក៏ប្រឡងដែរ ហើយខ្ញុំប្រកបត្រូវគ្រប់ពាក្យ។ ចុះយ៉េកវិញពូកែខាងអ្វីដែរ? »



យ៉េកឆ្លើយ « ខ្ញុំខ្ពស់ ហើយខ្ញុំអាចឈោងដៃដល់កន្លែងខ្ពស់ៗជាច្រើន »



លោកគ្រូសុខក៏ឆ្លើយដែរ « លោកគ្រូវិញមានកម្លាំងខ្លាំង។ លោកគ្រូអាចលើករបស់ធ្ងន់ៗបានជាច្រើន »



ចំណែកឯ ខេទីវិញនៅស្ងៀម។« ចុះខេទីវិញ? តើអ្នកពូកែខាងអ្វីដែរ? »ខេទីគិតមួយសន្ទុះ
រួចក៏សម្រេចចិត្តឆ្លើយទាំងទឹកមុខស្រពាប់ស្រពោន « ខ្ញុំគិតថា ខ្ញុំដូចជាអត់មានពូកែខាងអ្វីសោះហើយ »



និយាយដល់ត្រឹមនេះ ពួកគាត់ក៏ជិះមកដល់កន្លែង ដែលលោកគ្រូសុខចូលចិត្តមកអង្គុយលំហែកាយលេង។ លោកគ្រូសុខក៏បាននិយាយ « ឱ្យតែលោកគ្រូមានពេលទំនេរ លោកគ្រូចូលចិត្តមកទីនេះលេងហើយ »។



មករាលាន់មាត់ « ខ្ញុំស្រេកទឹកណាស់ »រតនាក៏ឆ្លើយ « អូ! អត់បានទេ » រតនានិយាយទាំងយំ
« យើងភ្លេចយកទឹកមកបាត់ទៅហើយ។ តើគួរធ្វើយ៉ាងណាទៅ? »



មករាក៏មានយោបល់ « ប្រហែលជាពួកយើងអាចបេះផ្លែដូងនៅដើមនេះបាន។ តើធ្វើយ៉ាងណាទើបបេះផ្លែដូងបានទៅណ៎? »




រតនារាប់ផ្លែដូងទាំងអស់ ដែលនៅលើដើមដូងនោះ។ នាងក៏បូកដកឃើញថា បើពួកគេអាចបេះដល់ពួកគេនឹងបានផ្លែដូងម្នាក់មួយ




ហើយនៅសល់ដូងពីរផ្លែទៀតផង

តែប៉ូកដកបែបនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាននោះទេ។




មករាក៏និយាយ « ខ្ញុំអាចប្រកបពាក្យផ្លែដូងបានយ៉ាងល្អ។ ផ ជើង ល ដាក់ស្រៈ ែ ផ្លែ ដ ដាក់ស្រៈ ូ នឹង ង ខ្ញុំអានថាផ្លែដូង »




តែការដែលមកាចេះប្រកបពាក្យផ្លែដូងដូចនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាន សូម្បីតែមួយផ្លែឡើយ។



យ៉េកខំឈរចង្អើត លើកដៃឈោងទៅលើ តែទោះជាគាត់អាចលើកដៃបានខ្ពស់ប៉ុណ្ណាក៏ដោយ
ក៏មិនខ្ពស់ដល់ថ្នាក់អាចបេះផ្លែដូងបានដែរ។



លោកគ្រូសុខឱនក្បាលចុះ ហើយរត់សម្រុកទៅបុកដើមដូងពេញមួយទំហឹង។ គាត់គិតថា ធ្វើយ៉ាងនេះ
អាចធ្វើឱ្យផ្លែដូងរង្គើធ្លាក់ចុះក្រោម។



តែចុងក្រោយ បែរជាគ្មានផ្លែដូងណាធ្លាក់មក សូម្បីតែមួយផ្លែសោះ។




ស្រាប់តែពេលនោះ មានដូងមួយផ្លែធ្លាក់មកក្ទុក នៅជិតតាតនាតែម្តង ធ្វើឱ្យពួកគាត់លោតភ្ញាក់ខ្លួនគ្រប់ៗគ្នា។




« ក្អុក! » ដូងមួយផ្លែទៀតធ្លាក់មកជិតមករាហើយ!

« ក្អុកៗ! »  « តើមានរឿងអ្វីកើតឡើងហ្នឹង? »



ពួកគេក៏នាំគ្នាងើយមើលទៅលើទាំងអស់គ្នា ឃើញខេទីនៅលើដើមដូង កំពុងបេះផ្លែដូងជិតបានមួយផ្លែទៀតហើយ!



« ក្នុក! » តោះទះដៃឱ្យខេទីទាំងអស់គ្នា ព្រោះគាត់បានជួយសង្គ្រោះអ្នកទាំងអស់គ្នាពីការស្រេកទឹកនៅគ្រានេះបានហើយ។



រតនាក៏និយាយ « ឃើញអត់ខេទី តាមពិតអ្នកពូកែទេតើ គឺពូកែខាងឡើងដើមឈើនោះអី »
មករាក៏និយាយបន្ត « មនុស្សម្នាក់ៗសុទ្ធតែពូកែមួយរឿងផ្សេងៗពីគ្នា »៕

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

TUKTUK

Rotary

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបន្ថែម៖ https://rermork.org/

មូលនិធិផ្តល់ដោយអង្គការTukTuk និងអង្គការរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ **Robert McCurdy** និង**Roberta Dahl** ជាអ្នកស្ម័គ្រចិត្តដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង **Sally Heinrich** ដែលបានចូលរួមកែសម្រួល និងបកប្រែសៀវភៅរឿងនេះ។

ទទួលបានព័ត៌មានបន្ថែម

ទទួលបានគំនូរជីវចល

ទទួលបានធនធានបន្ថែម